CDRI
Cambodia Development Resource Institute
LMPPI
Lower Mekong Public Policy Initiative

សង្ខេបសម្រាប់
គោលនយោបាយ

សីហា ២០១៧ លេខ ០១

# ការសិក្សាពីគោលនយោបាយស្រូវ៖ ផលពាក់ព័ន្ធនៃការផ្លាស់ប្តូរគោលនយោបាយស្រូវនៅវៀតណាម ទៅលើគោលនយោបាយស្រូវនៅកម្ពុជា និងអ្នកផលិតស្រូវអង្ករក្នុងបណ្តាខេត្តនៅភាគអាគ្នេយ៍

*ដោយ ស៊ឹម សុខចេង និង អៀ សុធី*

ថៃ វៀតណាម និង កម្ពុជា មានឈ្មោះល្បីថាជា ប្រទេសផលិតនិងនាំចេញអង្ករ។ នៅឆ្នាំ២០១៥ ថៃជាប្រទេសនាំចេញអង្ករច្រើនជាងគេលំដាប់ទី២ ដោយនាំចេញប្រមាណ ៩,៨ លានតោន (មានតម្លៃ៤,៥ប៊ីលានដុល្លារ)ហើយបន្ទាប់មកគឺវៀតណាមដែលបាននាំចេញប្រមាណ ៦,៦ លានតោន (២,៨ប៊ីលានដុល្លារ)។ ថៃនាំចេញអង្ករគុណភាពខ្ពស់(អង្ករក្រអូប)ជាចម្បងរីឯវៀតណាមផលិតនិងនាំចេញភាគច្រើននូវអង្ករមិនក្រអូប ឬអង្ករគុណភាពទាប។ អង្ករជាអាហារមូលដ្ឋាន និងជាដំណាំសំខាន់បំផុតនៅកម្ពុជា ហើយជាប្រភពចំណូលសំខាន់សម្រាប់គ្រួសារ ៨៥% នៅជនបទ។ ស្រូវអង្ករចូលរួមចំណែក ប្រមាណ ៤,៥% ក្នុងផលិតផលក្នុងស្រុកសរុប (ផសស) និង ២០% នៃចំណូលសរុបក្នុងគ្រួសារ។ ប៉ុន្តែស្រូវអង្ករក៏ចោទបញ្ហាច្រើនណាស់ដែរនៅកម្ពុជា ជាពិសេស បញ្ហាពាក់ព័ន្ធនឹងទីផ្សារ។ នៅឆ្នាំ២០១៤ កម្ពុជាផលិតស្រូវក្រអូប និងមិនក្រអូប បានប្រមាណ ៩,៣ លានតោន។

នៅឆ្នាំ២០១៥ កម្ពុជាបាននាំចេញអង្ករជាផ្លូវការប្រមាណ ០,៥ លានតោនទៅអឺរ៉ុប និងបណ្តាប្រទេសអាស៊ាន។ ស្រូវនៅសល់ ត្រូវបានជួញដូរក្រៅផ្លូវការជាមួយប្រទេសជិតខាង មាន ថៃ និង វៀតណាម។ កសិករនៅតាមព្រំដែន ក្នុងបណ្តាខេត្តនៅភាគអាគ្នេយ៍ (តាកែវ ព្រៃវែង ស្វាយរៀង) តែងលក់ស្រូវប្រាំងភាគច្រើនរបស់ខ្លួនទៅវៀតណាម តាមរយៈ ឈ្មួញវៀតណាម ឬឈ្មួញកម្ពុជា។ ឈ្មួញវៀតណាមជាអ្នកកំណត់តម្រូវការ និងថ្លៃស្រូវប្រាំង ហើយស្ថានភាពនេះបង្កនូវអស្ថិរភាព និងភាពមិនច្បាស់លាស់ដល់កសិករដែលកំពុងគិតគូរកែលំអផលិតភាព និងបង្កើនផលិតកម្មស្រូវ។

នាពេលថ្មីៗ រដ្ឋាភិបាលវៀតណាម បានផ្លាស់ប្តូរគោលនយោបាយកសិកម្ម ជាពិសេសគោលនយោបាយស្រូវ ចេញពីស្រូវមានទិន្នផលខ្ពស់និងគុណភាពទាប (ស្រូវមិនក្រអូប) ទៅផ្តោតលើ ស្រូវមានទិន្នផលទាបតែមានគុណភាពខ្ពស់ (ស្រូវក្រអូប) វិញ។ ប្រព័ន្ធនាំចេញអង្កររបស់វៀណាមបានផ្លាស់ប្តូរយ៉ាងខ្លាំង ក្នុងឆ្នាំប៉ុន្មានថ្មីៗ។ អង្ករក្រអូបកាន់តែដើរតួនាទី

តារាង១៖ សមតុល្យស្រូវអង្ករនៅប្រទេសកម្ពុជា

| វាយលំអិត | តោន |
|---|---|
| ផលិតកម្ម (ស្រូវ) | 9324170 |
| គ្រាប់ពូជ | 684500 |
| នៅសល់សម្រាប់តម្រូវការផ្សេងទៀត (ស្រូវ) | 8639670 |
| នៅសល់សម្រាប់តម្រូវការផ្សេងទៀត (គិតជាអង្ករ) | 4751819 |
| ប្រើប្រាស់អស់សរុប (អង្ករ) | 2703447 |
| ប្រើប្រាស់អស់នៅជនបទ (អង្ករ) | 2241229 |
| ទីផ្សារនៅទីប្រជុំជនក្នុងមូលដ្ឋាន (អង្ករ) | 186846 |
| ជំនួញអន្តរខេត្ត (អង្ករ) | 275372 |
| ការនាំចេញអង្ករ | 538000 |
| អង្ករប្រើប្រាស់អស់សរុប | 3241447 |
| នាំចេញក្រៅផ្លូវការ (គិតជាអង្ករ) | 1510371 |
| នាំចេញសរុប (គិតជាអង្ករ) | 2048371 |
| នាំចេញក្រៅផ្លូវការ (គិតជាស្រូវ) | 2746130 |

ប្រភព៖ Frédéric Lançon (CIRAD) 2016

លោក ស៊ឹម សុខចេង ជាអ្នកស្រាវជ្រាវ និងជាប្រធានផ្នែកកសិកម្ម និង អៀ សុធី ជាអតីតអ្នកស្រាវជ្រាវផ្នែកកសិកម្ម។ សូមយោងឯកសារនេះថា៖ Sim Sokcheng and Ear Sothy. 2017. *Rice Policy Study: Implications of Rice Policy Changes in Vietnam for Cambodia's Rice Policy and Rice Producers in Southeastern Provinces*. Policy Brief 2017 No. 01. Phnom Penh: CDRI.

សំខាន់ក្នុងការនាំចេញរបស់វៀតណាម ហើយនិន្នាការនេះទំនងបន្តទៅមុខទៀតព្រោះក្រសួងកសិកម្មនិងអភិវឌ្ឍជនបទ (MARD) បានបញ្ជាក់ថា វៀតណាមគួរផ្តោតខ្លាំងថែមទៀតទៅលើការផលិតអង្ករមានតម្លៃខ្ពស់ សម្រាប់ការនាំចេញ។ គេរំពឹងថាផលិតកម្ម និងការនាំចេញអង្ករមានគុណភាពទាបរបស់វៀតណាមនឹងធ្លាក់ចុះ។ ពាណិជ្ជករ និងអ្នកនាំចេញអង្កររបស់វៀតណាមនឹងប្រមូលទិញកាន់តែច្រើននូវអង្ករមានតម្លៃខ្ពស់ ហើយកាត់បន្ថយការទិញអង្ករមានគុណភាពទាប ពីផលិតករអង្ករវៀតណាមនិងកម្ពុជា។

កសិករនៅភាគអាគ្នេយ៍នៃប្រទេសកម្ពុជា ភាគច្រើនដាំស្រូវ IR504 ដែលត្រូវពឹងផ្អែកខ្លាំងទៅលើតម្រូវការពីពាណិជ្ជករវៀតណាម។ ដូច្នេះការសិក្សានេះមានផ្តល់មតិឲ្យពិចារណាល្អិតល្អន់ពី ផលពាក់ព័ន្ធនៃការផ្លាស់ប្តូរគោលនយោបាយស្រូវនៅវៀតណាម មកលើផលិតកម្មស្រូវនៅកម្ពុជា ជាពិសេស ផលប៉ះពាល់ទៅលើប្រាក់ចំណូលរបស់គ្រួសារនៅតាមជនបទ ក្នុងតំបន់នានានៅភាគខាងកើត និងខាងត្បូង ជាប់នឹងព្រំប្រទល់ប្រទេសវៀតណាម។

## ការផ្លាស់ប្តូរគោលនយោបាយកសិកម្មនៅវៀតណាម

ការសិក្សាឯកសារមានស្រាប់ និងការធ្វើសម្ភាស៍ជាមួយអ្នកតំណាងវិស័យសាធារណៈ និងវិស័យឯកជនវៀតណាម បង្ហាញថា រដ្ឋាភិបាលវៀតណាម ពិតជាបាននិងកំពុងផ្លាស់ប្តូរគោលនយោបាយកសិកម្ម។ ក្រុមហ៊ុននាំចេញមួយចំនួន បានចាប់ផ្តើមនាំចេញអង្ករមានតម្លៃខ្ពស់ ហើយបានចំណេញកាន់តែច្រើនឡើង។ កសិករវៀតណាមខ្លះ ក៏កំពុងគិតគូរផ្លាស់ប្តូរទៅដាំស្រូវមានតម្លៃខ្ពស់ដែរ ប៉ុន្តែ អ្នកដែលបានផ្លាស់ប្តូររួចហើយ មិនទាន់មានច្រើននាក់ទេ។ កសិករនៅដីសណ្តទន្លេមេគង្គ កំពុងដាំពូជស្រូវមានតម្លៃទាបនៅឡើយ ព្រោះគាត់ធ្លាប់ដាំវាជាយូរឆ្នាំ ហើយទីផ្សារក៏នៅមានតម្រូវការ។ សរុបមក ទាំងអ្នកតំណាងវិស័យសាធារណៈ និងវិស័យឯកជន បានបញ្ជាក់ថា គោលនយោបាយនេះនៅថ្មីថ្មោង ដូច្នេះត្រូវការពេលច្រើនដើម្បីដាក់អនុវត្ត។ ដូច្នេះអាចរហូតដល់រយៈពេលមធ្យមឯណោះ ទើបរដ្ឋាភិបាលមានផែនការជាក់លាក់ជាងនេះ ដោយស្វែងរកទីផ្សារថ្មីៗមានស្ថិរភាពល្អ និងជួយកសិករឲ្យទទួលបានព័ត៌មានគ្រប់គ្រាន់ ហើយសម្របខ្លួនទៅតាមនោះ។ ដូច្នេះឈ្មួញវៀតណាមទំនងជា មិនកាត់បន្ថយការទិញស្រូវអង្ករមានតម្លៃទាប ពីប្រទេសកម្ពុជាក្នុងពេលឆាប់ៗនេះទេ។

## ស្ថានភាពវិស័យស្រូវអង្ករនៅភាគអាគ្នេយ៍ប្រទេសកម្ពុជា

កសិករក្នុងខេត្តទាំងបីនៅជាប់ព្រំដែន ធ្វើទាំងស្រូវប្រាំង និងស្រូវវស្សា។ ស្រូវប្រាំងគេផលិតជាសំខាន់សម្រាប់លក់ រីឯស្រូវវស្សា គឺសម្រាប់ការប្រើប្រាស់ក្នុងគ្រួសារ។ កសិករមួយចំនួនក៏លក់ដូរស្រូវវស្សាដែលលើសពីតម្រូវការរបស់ខ្លួនដែរ។ ពូជស្រូវប្រាំងដែលមានដាំច្រើនជាងគេគឺ IR504 រីឯពូជស្រូវវស្សាមានដាំច្រើនជាងគេគឺស្រូវក្រអូប។កសិករនៅតាមតំបន់បានធ្វើអង្កេតគាត់តែងលក់ស្រូវនៅសើម ដោយគ្មានការកែច្នៃបង្កើតតម្លៃបន្ថែមអ្វីទេ ធ្វើឲ្យស្រូវនៅតែមានថ្លៃទាប។ មានកសិករតិចនាក់ណាស់ដែលដាំបន្លែ។

ផលិតកម្មស្រូវនៅភាគអាគ្នេយ៍ប្រទេសកម្ពុជា ពឹងផ្អែកយ៉ាងខ្លាំងលើតម្រូវការពីវៀតណាម។ វៀតណាមជាអ្នកទិញធំជាងគេ និងមានឥទ្ធិពលខ្លាំងទៅលើថ្លៃស្រូវ។ ឈ្មួញកម្ពុជានៅតាមភូមិប្រមូលស្រូវលក់ទៅឲ្យទាំងរោងម៉ាស៊ីនកិនស្រូវកម្ពុជា និងឈ្មួញវៀតណាម ប៉ុន្តែស្រូវដែលលក់ទៅរោងម៉ាស៊ីនកិនស្រូវកម្ពុជាមានតែមួយភាគតូចប៉ុណ្ណោះ។ ឈ្មួញវៀតណាមខ្លះទៅដល់វាលស្រែមុនពេលស្រូវទុំ ហើយកំណត់ថ្ងៃត្រូវច្រូតកាត់ប្រមូលផល។ ក្នុងករណីនេះ កសិករខ្លះលក់ស្រូវទៅឲ្យឈ្មួញវៀតណាម។

រូបភាព១៖ លំហូរស្រូវអង្ករក្នុងបណ្តាខេត្តនៅភាគអាគ្នេយ៍ប្រទេសកម្ពុជា



តារាង២៖ ការប្រៀបធៀបចំណាយលើផលិតកម្មស្រូវ IR504 និងពូជស្រូវផ្សេងទៀត (ក្នុងមួយវដ្តផលិតកម្ម)

| ចំណាយផលិតកម្ម | IR504 | | រយៈពេលមធ្យម | | រយៈពេលវែង | | សរុប | |
|---|---|---|---|---|---|---|---|---|
| | រូបិយប័ណ្ណ | % | រូបិយប័ណ្ណ | % | រូបិយប័ណ្ណ | % | រូបិយប័ណ្ណ | % |
| គ្រាប់ពូជ (ដុល្លារ/ហិកតា) | 88.1 | 15.6 | 46.1 | 15.3 | 38.6 | 14.0 | 69.7 | 15.3 |
| ជួលពលកម្ម (ដុល្លារ/ហិកតា) | 7.7 | 1.4 | 10.7 | 3.6 | 5.5 | 2.0 | 7.5 | 1.7 |
| ទឹក (ដុល្លារ/ហិកតា) | 26.4 | 4.7 | 1.4 | 0.5 | 0 | 0.0 | 16.3 | 3.6 |
| ម៉ាស៊ីនបូមទឹក (ដុល្លារ/ហិកតា) | 39.4 | 7.0 | 9.2 | 3.1 | 2 | 0.7 | 25.7 | 5.7 |
| ម៉ាស៊ីនកសិកម្ម (ដុល្លារ/ហិកតា) | 107.5 | 19.1 | 91.8 | 30.5 | 113.8 | 41.2 | 107.2 | 23.6 |
| ជី (ដុល្លារ/ហិកតា) | 173.5 | 30.8 | 116.3 | 38.6 | 102.5 | 37.2 | 147.5 | 32.5 |
| ថ្នាំសម្លាប់សត្វចង្រៃ (ដុល្លារ/ហិកតា) | 120.7 | 21.4 | 25.9 | 8.6 | 13.6 | 4.9 | 80.5 | 17.7 |
| សរុបធាតុចូល (ដុល្លារ/ហិកតា) | **563.3** | **100.0** | **301.4** | **100.0** | **275.9** | **100.0** | **454.4** | **100.0** |
| ថ្លៃមធ្យម (ស្រូវស្ងួត) (រៀល/គ.ក) | 749.7 | - | 898.5 | - | 879.4 | - | 776.6 | - |
| ផលស្រូវ (ដុល្លារ/ហិកតា) | **827.2** | - | **508.9** | - | **487.4** | - | **697.4** | - |
| ចំណេញ (ដុល្លារ/ហិកតា) | **263.9** | - | **207.5** | - | **211.5** | - | **243** | - |

## ការចំណាយ និងផលចំណេញលើដំណាំស្រូវផ្សេងៗ

ការវិភាគចំណាយនិងផលចំណេញបង្ហាញថា ពូជស្រូវ IR504 ហុចផលចំណេញច្រើនជាងគេ ដល់គ្រួសារនៅក្នុងតំបន់ចុះសិក្សា។ ប៉ុន្តែស្រូវ IR504 ត្រូវមានការប្រើជី ថ្នាំសម្លាប់សត្វចង្រៃ និងទឹកយ៉ាងច្រើន ហើយបទពិសោធន៍នៅវៀតណាមបង្ហាញថា ការប្រើប្រាស់ជី និងថ្នាំសម្លាប់សត្វចង្រៃក្នុងបរិមាណខ្ពស់ អាចបណ្តាលឲ្យខូចគុណភាពដីនិងទឹកយ៉ាងធ្ងន់ធ្ងរ។ បទពិសោធន៍នេះផ្តល់គំនិតថា កសិករគួរប្តូរចេញពីស្រូវ IR504 ទៅប្រើពូជស្រូវកណ្តាលវិញ ដែលទាមទារការប្រើវត្ថុធាតុដើមតិចជាង ជាពិសេស ថ្នាំសម្លាប់សត្វចង្រៃ និងជីគីមី។ ស្រូវកណ្តាលមានទិន្នផលទាបជាងក៏ពិតមែន ប៉ុន្តែស្រូវនេះលក់បានថ្លៃខ្ពស់ជាងស្រូវ IR504។ ថ្លៃស្រូវកណ្តាលអាចកើនឡើងមួយជាបី ប្រសិនបើកសិករលក់ជាស្រូវស្ងួត ឬអង្ករ។ ដូច្នេះសម្រាប់ផលប្រយោជន៍សេដ្ឋកិច្ចក្នុងរយៈពេលវែង និងដើម្បីឲ្យផលិតកម្មស្រូវមានចីរភាព គួរលើកស្ទួយពូជស្រូវកណ្តាលឲ្យបានយ៉ាងទូលំទូលាយ ក៏ដូចជាតម្រូវការទីផ្សារ និងកម្រិតថ្លៃមានស្ថិរភាពល្អ។

## ឥទ្ធិពលនៃការផ្លាស់ប្តូរតម្រូវការពីវៀតណាម

វិបត្តិក្នុងតម្រូវការស្រូវពីប្រទេសវៀតណាម មានផលប៉ះពាល់អវិជ្ជមានដល់ជីវភាពគ្រួសារ ជាពិសេសគ្រួសារដែលមានប្រភពចំណូលចម្បងពីការធ្វើស្រែ។ អង្កេតគ្រួសារបង្ហាញថា ប្រមាណ ២០% នៃគ្រួសារសំណាក រកបានប្រាក់ចំណូលជាង ៥០% ពីការធ្វើស្រែ ហើយនឹងត្រូវប៉ះពាល់យ៉ាងខ្លាំង ប្រសិនបើឈ្មួញវៀតណាមឈប់ទិញស្រូវគាត់។

រោងម៉ាស៊ីនកិនស្រូវ និងឈ្មួញក្នុងតំបន់ចុះសិក្សា មិនមានលទ្ធភាពស្រូបយកស្រូវដែលលើសពី តម្រូវការក្នុងស្រុកនោះទេ ប្រសិនបើវៀតណាមឈប់ទិញស្រូវ។ ការកិនពូជស្រូវមានតម្លៃទាប ដូចជា IR504 ជាដើម មានអត្រាចំណេញទាបខ្លាំងណាស់ ឬក៏គ្មានចំណេញសោះ។ ប៉ុន្តែរោងម៉ាស៊ីនកិនស្រូវត្រូវការទុនបង្វិល និងការប្រាក់ទាបដើម្បីពង្រីកសមត្ថភាពកិនស្រូវ។ នៅកម្ពុជាមានរោងម៉ាស៊ីនកិនស្រូវធំៗមួយចំនួនតូចដែរ ប៉ុន្តែដោយសារហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធឡូជីស្ទិកមិនទាន់មានគ្រប់គ្រាន់ ដូច្នេះក៏មិនអាចប្រមូលស្រូវប្រកបដោយប្រសិទ្ធភាព។ ម្យ៉ាងទៀត ដោយសារសព្វថ្ងៃកសិករចំណាយពេលតិចជាងមុនក្នុងការប្រមូលផលស្រូវ ដូច្នេះឈ្មួញ និងរោងម៉ាស៊ីនកិនស្រូវត្រូវពង្រីកការទិញចូលក្នុងរដូវច្រូតកាត់ ហើយត្រូវមានកន្លែងស្តុកស្រូវធំ និងមានសមត្ថភាពខ្ពស់ក្នុងការសម្ងួត និងកិនស្រូវ។

វិស័យសាធារណៈនៅកម្ពុជាដឹងច្បាស់ពី សារៈសំខាន់នៃទីផ្សារសម្រាប់កសិផល ហើយកំពុងស្វែងរកទីផ្សារថ្មីៗ ដើម្បីធ្វើពិពិធកម្មចេញពី ការពឹងផ្អែកលើទីផ្សារនៅប្រទេសជិតខាង។ ចិនជាប្រទេសមួយដែលមានជោគជ័យ ក្នុងការស្វែងរកទីផ្សារអង្ករថ្មីៗ។ រដ្ឋាភិបាលកំពុងលើកទឹកចិត្តកសិករឲ្យដាំ ពូជស្រូវកណ្តាលប្រភេទក្រអូប និងបានកំណត់ពូជស្រូវ ១០ មុខ ដែលកសិករគួរដាំដុះសម្រាប់បម្រើការនាំចេញ។

## ការផ្តល់មតិ

ក្នុងរយៈពេលខ្លី

- ដើម្បីជៀសវាងវិបត្តិផ្នែកតម្រូវការ រដ្ឋាភិបាលកម្ពុជាគួរស្វែងរកកិច្ចព្រមព្រៀងទ្វេភាគីជាមួយរដ្ឋាភិបាលវៀតណាម ដោយមានការសម្របសម្រួលរវាងអាជ្ញាធរកម្ពុជា និងវៀតណាមនៅតាមព្រំដែនផង ដើម្បីយ៉ាងហោចណាស់អាចរក្សាបាននូវស្ថានភាពបច្ចុប្បន្ន និងធានាឲ្យមានទីផ្សារនាំចេញស្រូវសម្រាប់កសិករកម្ពុជា។
- ដើម្បីបង្កើតដំណោះស្រាយផ្នែក គោលនយោបាយសម្រាប់បង្កើនប្រសិទ្ធភាពផលិតកម្ម ជំនះភាពទន់ខ្សោយនៃប្រព័ន្ធផលិតកម្ម និងបង្កើនប្រសិទ្ធភាពខ្សែសង្វាក់តម្លៃអង្ករ គឺត្រូវរក្សាឲ្យបាននូវរចនាសម្ព័ន្ធផលិតកម្មមានស្រាប់ សម្រាប់រយៈពេលក្រោយនោះទៀត។ ការធ្វើស្រូវ IR504 តាមបែប

☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ +៨៥៥២៣៨៨១៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣
🖷 +៨៥៥២៣៨៨០៧៣៤ អ៊ីមែល៖ cdri@cdri.org.kh; www.cdri.org.kh

ប្រពលវប្បកម្ម ដោយប្រើជីគីមី និងថ្នាំសម្លាប់សត្វចង្រៃច្រើនៗ អាចបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាពមនុស្ស និងបរិស្ថានជុំវិញ ជាពិសេស គុណភាពដីនិងទឹក។ ដូច្នេះការបណ្តុះបណ្តាលកសិករពីរបៀបទុកដាក់និងប្រើប្រាស់ជីនិងថ្នាំសម្លាប់សត្វចង្រៃឲ្យបានត្រឹមត្រូវ ជាការចាំបាច់បំផុត។

## ក្នុងរយៈពេលវែង

- ការលក់ស្រូវសើមគឺជាការខាតបង់ដល់កសិករ ហើយការនាំចេញស្រូវសើមគឺជាការខាតបង់ដល់ប្រទេសជាតិ។ ដូច្នេះកម្ពុជាគួរជំរុញផលិតកម្មកសិកម្ម ដើម្បីជួយឲ្យកសិករអាចទ្រទ្រង់ជីវភាពបានយូរអង្វែង។ កម្ពុជាមានប្រព័ន្ធអេកូឡូស៊ីអំណោយផលសម្រាប់ ការដាំដុះពូជស្រូវជាប្រពៃណីដែលមានតម្លៃខ្ពស់ ព្រោះមានបរិស្ថានស្អាត និងការប៉ះពាល់តិចជាងជាមួយនឹងសារធាតុគីមីកសិកម្ម បើធៀបនឹងប្រទេសនាំចេញអង្ករយូរឆ្នាំមកហើយដូចជាវៀតណាម។ ហេតុនេះរដ្ឋាភិបាលគួរចាប់យកឱកាសល្អពី លក្ខខណ្ឌអនុគ្រោះសម្រាប់ការនាំចេញទៅទីផ្សារអឺរ៉ុប ដោយលើកកម្ពស់ស្រូវអង្ករកម្ពុជាដែលមានគុណភាពខ្ពស់ និងបន្ថែមតម្លៃច្រើន។ ហើយដើម្បីជំរុញផលិតកម្មអង្ករក្រអូប ត្រូវមានវិនិយោគច្រើនៗទៅលើហេដ្ឋារចនាសម្ព័ន្ធដូចជាប្រព័ន្ធស្រោចស្រពនិងរំដោះទឹក សេវាដឹកជញ្ជូន និងសមត្ថភាពកែច្នៃផលិតផល។ ម្យ៉ាងទៀត ដើម្បីបានប្រើប្រាស់ទីផ្សារថ្មីៗទាំងនេះ ក្នុងពេលដែល សមត្ថភាពក្រុមហ៊ុនកម្ពុជានៅមានកម្រិត ហើយហេដ្ឋារចនាសម្ព័ន្ធក៏មិនទាន់មានគ្រប់គ្រាន់នោះ វិធីសាស្ត្រប្រសើរបំផុត គឺ គួរបង្កើតទំនាក់ទំនងជាមួយសហគ្រាសវៀតណាម និងទាក់ទាញពួកគេឲ្យមកធ្វើវិនិយោគដើម្បីកែលំអសមត្ថភាពស្តុកនិងកែច្នៃផលិតផល ក៏ដូចជាជួយឲ្យកម្ពុជាអាចកាន់តែសកម្មក្នុងការបង្កើន ទំនិញនាំចេញមានតម្លៃបន្ថែមខ្ពស់។
- ទីផ្សារសម្រាប់អង្ករក្រអូបត្រូវតែធ្វើពិពិធកម្ម និងមានសុវត្ថិភាពល្អ។ ដោយហេតុថា វៀតណាមបានរៀបចំគោលនយោបាយស្រូវអង្កររបស់ខ្លួនឡើងវិញ តាមការផ្លាស់ប្តូរទៅផលិតអង្ករមានតម្លៃខ្ពស់នោះ ដូច្នេះកម្ពុជាក៏អាចបន្ស៊ីផលិតកម្មរបស់ខ្លួនដោយផលិតអង្ករ (ក្រអូប) ដែលមានតម្លៃខ្ពស់ឲ្យបានកាន់តែច្រើន ដើម្បីបំពេញតាមកំណើនតម្រូវការពីវៀតណាម។ កសិកម្មតាមកិច្ចសន្យាគួរតែជំរុញឡើង និងអនុវត្តឲ្យបានទូលំទូលាយ ដើម្បីធានាឱ្យមានទីផ្សារសម្រាប់កសិករ។ សហគ្រាសកម្ពុជាភាគច្រើននឹងជួបការលំបាកក្នុងការឆ្លើយតបឲ្យបានរហ័សទៅនឹង តម្រូវការក្នុងពេលអនាគតដ៏ខ្លីខាងមុខ ដោយសារនៅមានសមត្ថភាពទន់ខ្សោយនៅឡើយ។ ដូច្នេះគួរគិតគូរបង្កើតគោលនយោបាយនានាដើម្បីជំរុញការកសាងអង្គការកសិករ ព្រោះបទពិសោធម៍នៅអន្តរជាតិបង្ហាញថា អង្គការកសិករជាកត្តាសំខាន់សម្រាប់ការរស់រាន និងចីរភាពនៃការធ្វើកសិកម្មតាមកិច្ចសន្យា។
- កែលំអស្ថានភាពបច្ចុប្បន្ន ព្រមទាំងឈានទៅអនុវត្តគំរូថ្មី។ រដ្ឋាភិបាលគួរយកចិត្តទុកដាក់ខ្លាំងលើ គោលនយោបាយសម្រាប់អភិវឌ្ឍនិងការពារទីផ្សារ និងជំរុញសហប្រតិបត្តិការវិនិយោគ ជាជាងគោលនយោបាយសម្រាប់ផ្តល់ឧបត្ថម្ភធនដល់ផលិតកម្ម ក្នុងការជួយកសិករឲ្យបង្កើនផលិតកម្មស្រូវអង្ករ និងប្រាក់ចំណេញ។

